# យុត្តិធម៌សម្រាប់ជនរងគ្រោះ

ចាប់ផ្តើមដោយការបណ្តេញប្រជាជនទាំងអស់ចេញពីទីក្រុងនានា ហើយបំពេញមកវិញនូវរណ្តៅកប់សាកសពយ៉ាងច្រើននៅរាយប៉ាយពាសពេញផ្ទៃប្រទេស ទីបំផុតរបបវាលពិឃាដមួយបានសម្លាប់ប្រជាជនខ្លួនឯងអស់មួយលានប្រាំពីរសែននាក់តែក្នុងរយៈពេលបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃប៉ុណ្ណោះ ។

ប្រជាជនកម្ពុជាគ្រប់ៗរូបដែលរួចផុតពីការស្លាប់ ហើយដែលបច្ចុប្បន្នមានអាយុចាប់ពីសែសិបឆ្នាំឡើងទៅ សុទ្ធតែមានរឿងនិទានដ៏សែនរំជួលចិត្តផ្ទាល់ខ្លួនម្នាក់ៗ ។ គឺជារឿងនិទានដែលរំឭកឡើងវិញអំពីរឿងរ៉ាវពិតក្នុងឆាកជីវិតរបស់ខ្លួនដែលបានជួបប្រទះនូវទុក្ខវេទនា ការនិរាសព្រាត់ប្រាស់ ការបែកបាក់គ្រួសារ ។ រឿងនិទានដែលរៀបរាប់អំពីការបង្ខំឲ្យធ្វើពលកម្មដ៏សែនធ្ងន់ធ្ងរ រឿងនិទានដែលរៀបរាប់អំពីការអត់ឃ្លានហួសនិស្ស័យ រឿងនិទានដែលរៀបរាប់អំពីទារុណកម្មលើរូបរាងកាយនិងផ្លូវចិត្តដែលកម្មាភិបាលខ្មែរក្រហមនៅតាមមូលដ្ឋានបានប្រព្រឹត្តិមកលើខ្លួនផ្ទាល់និងចំពោះសាច់ញាតិបងប្អូនឪពុកម្តាយ ។

រឿងរ៉ាវពិតដែលពោរពេញដោយការរំជួលចិត្តមិនអាចទប់ទឹកភ្នែកបានទាំងអស់នោះបានចាប់ផ្តើមឡើងកាលពីសាមសិបឆ្នាំមុន ហើយបានបន្តឲ្យមានរបួសស្នាមដល់អារម្មណ៍និងផ្លូវចិត្តជនរងគ្រោះទាំងអស់ក្នុងរបបខ្មែរក្រហមរហូតមកដល់សព្វថ្ងៃនេះ ។ វិធីតែមួយគត់ក្នុងការព្យាបាលស្នាមរបួសផ្លូវចិត្តទាំងអស់នោះ គឺគ្មានអ្វីក្រៅពីការផ្តល់ឲ្យជនរងគ្រោះគ្រប់ៗរូបនូវយុត្តិធម៌ដ៏ថ្លៃថ្នូរមួយ ។ គឺជាយុត្តិធម៌ដែលមិនមែនជាការសងសឹក ។

ពេលវេលាបីទសវត្សរ៍ដែលបានកន្លងផុតទៅបានធ្វើឲ្យវ័យអ្នកដែលសល់ពីស្លាប់និងអ្នកទទួលខុសត្រូវក្នុងការស្លាប់កាន់តែចាស់ជរាទៅៗ ។ អ្នកទទួលខុសត្រូវខ្លះដូចជា ប៉ុល ពត, សុន សេន និង កែ ពក ជាដើម បានស្លាប់ទៅបាត់ទទេដោយគ្មានបានពន្យល់បំភ្លឺដល់ជនរងគ្រោះបានស្តាប់ឮដោយផ្ទាល់ពីមូលហេតុដែលនាំឲ្យក្រុមខ្លួនបង្កើតឲ្យមានរបបវាលពិឃាដ ។ ទាំង ប៉ុល ពត, សុន សេន និង កែ ពក សុទ្ធតែមិនបានដឹងថា អតីតសមមិត្តដ៏ជិតស្និទ្ធរបស់ខ្លួនដែលមានជីវិតរស់នៅរហូតមកដល់សព្វថ្ងៃនេះកំពុងតែមិនហ៊ានប្រឈមមុខនឹងការពិតនូវទង្វើរបស់ខ្លួនពីអតីតកាលទេ ហើយពេញចិត្តនឹងភាពកំសាកមិនទទួលខុសត្រូវអ្វីទាំងអស់ ។ ចំណែកឯជនរងគ្រោះទាំងអស់ (ទាំងអ្នកស្លាប់និងអ្នកនៅរស់) ក៏មិនទាន់ទទួលបាននូវយុត្តិធម៌ដែលបានមកពីការកាត់ទោសដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិដែរ ។

តើដល់ពេលណាទៅទើបយុត្តិធម៌ត្រូវបានផ្តល់ឲ្យជនរងគ្រោះគ្រប់ៗរូបក្នុងរបបវាលពិឃាដ?

សូមឲ្យតុលាការកាត់ក្តីខ្មែរក្រហមកើតមានឡើងឲ្យបានឆាប់ ដើម្បីបិទទំព័រប្រវត្តិសាស្ត្រដ៏ជូរចត់ខ្មៅងងឹតនេះសំដៅព្យាបាលស្នាមរបួសផ្លូវចិត្តដល់ជនរងគ្រោះទាំងអស់និងក្នុងន័យផ្សះផ្សាជាតិពិតប្រាកដ ។ នេះគឺជាការអំពាវនាវដ៏ទទូចក្នុងនាមជាជនរងគ្រោះម្នាក់ក្នុងរបបខ្មែរក្រហម ។ **ម៉េង រស្មី**

## សេចក្តីប្រកាសរកប្អូនប្រុសពីរនាក់

នាងខ្ញុំឈ្មោះ អាន គៅ ភេទស្រី អាយុ៥៨ឆ្នាំ រស់នៅភូមិព្រៃម៉ីយ៍ ឃុំដាន់ញឹម (អតីតភូមិដើម ឃុំនីរពេជ្រ) ស្រុកប្រាសាទបាល័ង្គ (កំពង់ស្វាយ) ខេត្តកំពង់ធំ ។

សូមសួររកប្អូនប្រុសឈ្មោះ អាន កួយ និង អាន គុយ ដែលបានចេញពីផ្ទះទៅធ្វើកងទ័ពខ្មែរក្រហមនៅឆ្នាំ១៩៧២ ។ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ កួយ បានមកលេងផ្ទះម្តងរយៈពេល៤-៥ថ្ងៃ រួចក្រោយមកក៏បាត់ដំណឹងរហូតដល់សព្វថ្ងៃ ។

បើសាមីខ្លួនបានឮឬបងប្អូនបានស្គាល់ឈ្មោះខាងលើ សូមផ្តល់ព័ត៌មានមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើតាមប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។